ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០៦
ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២២
សាលដីកា
លេខ ១៨៣ "II"
ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣

# សាលដីកា
# តាមនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២៣
ដោយក្រុមប្រឹក្សាជំនុំជម្រះមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន
២. លោកជំទាវ [redacted] ជាចៅក្រម
៣. ឯកឧត្តម [redacted] ជាចៅក្រម
៤. ឯកឧត្តម [redacted] ជាចៅក្រម
៥. លោកជំទាវ [redacted] ជាចៅក្រម

## ចៅក្រមរបាយការណ៍

ឯកឧត្តម [redacted]

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ០០១ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ហ្វសានី ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១៥៣/១៩ ព្រទ.ក្រ$_{VI}$ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រះសីហនុ ដែលមាន ៖

**-ជនជាប់ចោទ ៖**

១-ឈ្មោះ [redacted] ហ្វសានី ហៅ លីប ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ-ឥស្លាម មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិអូរគ្រាវ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងមានទីលំនៅមុនពេលឃុំខ្លួន [redacted] ខេត្តព្រះសីហនុ ។ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ


មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia
Scanned with CamScanner

[redacted]"រ" នៅលីវ ទោសពីមុនគ្មាន ។ (ឃុំខ្លួនថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០២០ នៅពន្ធនាគារខេត្តព្រះសីហនុ)
(អ្នកប្ដឹងសាទុក្ខ )

-មានលោក [redacted] ឃួរ៉ា និងលោក [redacted] ច័ន្ទតារា ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ហួសានី ហៅ លីប ។

២-ឈ្មោះ [redacted] លី ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ-ឥស្លាម មុខរបរកម្មកររោងចក្រ មានទីកន្លែងកំណើតនៅភូមិត្រាវ ឃុំអណ្ដូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងមានទីលំនៅមុនពេលឃុំខ្លួន [redacted]ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ ឪពុកឈ្មោ[redacted] "រ" ម្ដាយឈ្មោះ [redacted]" ទោសពីមុនគ្មាន ។ (ឃុំខ្លួនថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០២០)

-ជាប់ចោទពីបទ ៖ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុចទី៤ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣-ឈ្មោ[redacted]ច័ន្ទរ៉ាយ៉ុន ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិ០១ ឃុំស្មាច់ដែង ស្រុកដងទង់ ខេត្តកោះកុង និងមានទីលំនៅមុ[redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ ឪពុកឈ្មោះ[redacted]រ" ម្ដាយឈ្មោះ [redacted]" ប្រពន្ធឈ្មោះ[redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ។ (ឃុំខ្លួនថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០២០)

-ជាប់ចោទពីបទ ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុចទី៤ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-ឈ្មោ[redacted]កាម៉ាល់ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ-ឥស្លាម មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងមានទីលំនៅមុនពេលឃុំខ្លួននៅ [redacted]រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ[redacted]" ទោសពីមុនគ្មាន ។ (ឃុំខ្លួនថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០២០)

-ជាប់ចោទពីបទ ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

# អង្គហេតុ

កាលពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២០ វេលាម៉ោង ១៥ និង ២៧ នាទី កម្លាំងសមត្ថកិច្ចជំនាញសហការជាមួយកម្លាំងមូលដ្ឋានស្រុកព្រៃនប់ បានចុះឆែកឆេរកឃើញមានគ្រឿងញៀន ប្រភេទម្សៅសថ្លា ចំនួនមួយកញ្ចប់ទម្ងន់ ០,៣៨ក្រាម ក្រោយពីធ្វើការសាកសួរកម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន ដោយឃាត់បានគ្រឿងញៀនចំនួន ៩៥,៤៦ក្រាម ដោយមានការទំនាក់ទំនងជាមួយនឹងឈ្មោះ ង៉ុក និងឈ្មោះ ហ៊ា ក្វ ដែលជាអ្នកលក់គ្រឿងញៀននៅរាជធានីភ្នំពេញ ។ បន្ទាប់មកកម្លាំងសមត្ថកិច្ចបានឈានទៅរកការឃាត់ឈ្មោះ [redacted] ហួសានី និងឈ្មោះ [redacted] លី ដោយមានការជាប់ពាក់ព័ន្ធនឹងការសមគំនិតក្នុងការលក់គ្រឿងញៀន ។ ក្រោយមកទើបកម្លាំងសមត្ថកិច្ចបានកសាងសំណុំរឿងដើម្បីចំណាត់ការតាមច្បាប់ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤២៤/៤៥ (ជ) ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-កែប្រែបញ្ញត្តិមាត្រាចំពោះជនជាប់ចោទឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន មាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ពីបទ ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកមាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច៦ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

២-កែប្រែបញ្ញត្តិមាត្រាចំពោះជនជាប់ចោទឈ្មោះ [redacted] ហួសានី និងឈ្មោះ [redacted] លី មាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ពីបទ ៖ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកមាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច៦ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ។

៣-ផ្ដន្ទាទោសជនជាប់ចោទ ៖

៣-១ ឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន ភេទប្រុស អាយុ ២៩ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៨(ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល ។

ពីបទ ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

៣-២ ឈ្មោះ [redacted] ហួសានី ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន)រៀល ។

៣-៣ ឈ្មោះ [redacted] លី ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន)រៀល ។

Scanned with CamScanner

ពីបទ ៖ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុចទី ៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣-៤ ឈ្មោះ [redacted] កាម៉ាល់ ភេទប្រុស អាយុ ៣០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០២(ពីរ)ឆ្នាំ ០៦ (ប្រាំមួយ)ខែ។

ពីបទ ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

៤-វត្ថុតាងរួមមាន៖

៤-១ គ្រឿងញៀនមេតំហ្វេតាមីន ចំនួន ៩៥,៤៦ ក្រាម ដែលដកហូតចេញពីឈ្មោ[redacted]ច័ន្ទរ៉ាយ៉ុន និងគ្រឿងញៀនមេតំហ្វេតាមីនចំនួន ០,៣៨ ក្រាម ដែលដកហូតពីឈ្មោះ[redacted]កាម៉ាល់ ដែកកេះចំនួនមួយ និងខ្សៀជក់ចំនួនមួយ តុលាការរឹបអូស និងបំផ្លាញចោល ។

៤-២ ទូរស័ព្ទចំនួនបួនគ្រឿង (អូប៉ូ១ អាហ្វូនស៊ិច១ ម៉ី២) និងប្រាក់រៀលចំនួន ២៤០.០០០ (ពីររយសែបសិបពាន់)រៀល តុលាការធ្វើការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

៥-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ ប៊ុន ច័ន្ទរ៉ាយ៉ុន ឈ្មោ[redacted]ហ្វូសាទី ឈ្មោះ [redacted] លី និងឈ្មោះ[redacted]កាម៉ាល់ ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៨៦ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ហ្វូសាទី ហៅ លីប ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤២៤/៤៥ (ជ) ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១៥៣/១៩ ព្រទ.ក្រ$_{៣}$ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨៦ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted] ហ្វូសាទី ទុកជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤២៤/៤៥ (ជ) ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហួសានី ។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ០០១ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ហួសានី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១៥៣/១៩ ព្រទ.ក្រ$_{\text{ព}}$ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រះសីហនុ គ្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សារណាការពារបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់លោក [redacted] តារាមុនន្ទ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ហួសានី ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២២ ។

**នាពេលសវនាការតុលាការកំពូល**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោ[redacted] ហួសានី ហៅ លីប ប្តឹងសាទុក្ខថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងផ្តន្ទាទោសរបស់តុលាការអង្គសេចក្តីដែលបានសម្រេចឡើយ គឺខ្លួនគ្រាន់តែប្រាប់អ្នកដែលចង់ទិញគ្រឿងញៀនឱ្យទំនាក់ទំនងទៅអ្នកលក់នៅភ្នំពេញប៉ុណ្ណោះ ។ ការលើកឡើងបានបង្ហាញនៅតុលាការអង្គសេចក្តីទាំង ២ ថ្នាក់រួចហើយ ដូចនេះការយល់ឃើញរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ព្រះសីហនុ តំណាងមហាអយ្យការយល់ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ក្នុងការចោទប្រកាន់ និងផ្តន្ទាទោស ។ ដូចនេះ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទមិនមានមូលហេតុដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។ ហេតុដូច្នេះតំណាងមហាអយ្យការស្នើសុំចំពោះតុលាការកំពូលសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៥៣/១៩ ព្រទ.ក្រ$_{\text{ព}}$ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ទុកជាបានការដដែល ។

-ជនជាប់ចោទឈ្មោះ [redacted] ហួសានី បានឆ្លើយថាមូលហេតុដែលខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលនេះគឺដោយសារខ្លួនមិនបានប្រព្រឹត្តអំពើសមគំនិតក្នុងការជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននោះទេ ខ្លួនគ្រាន់តែបានឱ្យលេខទូរស័ព្ទអ្នកលក់គ្រឿងញៀនទៅឱ្យទៅឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន តែប៉ុណ្ណោះ ហើយការឱ្យលេខទូរស័ព្ទនោះ គឺខ្លួនបានឱ្យទៅឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន តាំងពីមុនពេលចាប់ខ្លួន ៣ ទៅ ៤ខែមកហើយ ។ ដូច្នេះខ្លួនសំណូមពរសុំឱ្យឯកឧត្តមប្រធានជួយលើកលែងទោសឱ្យខ្លួនផង ។

-លោកមេធា[redacted]រ៉ា ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ហួសានី បានធ្វើសេចក្តីសន្និដ្ឋានថា មាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងអំពីមូលហេតុដែលបណ្តឹងសាទុក្ខអាចទទួលយកបាន



Scanned with CamScanner

ដោយតុលាការកំពូល ។ ក្នុងនោះ កង្វះសំអាងហេតុ គឺជាមូលដ្ឋានមួយ ។ សំអាងហេតុ សន្និដ្ឋានចេញជាបទល្មើស ការចូលរួមរបស់ជនជាប់ចោទ និងទោសទណ្ឌត្រូវតែច្បាស់លាស់ ទាញពីអង្គហេតុឯកភាព បានពីការស៊ើបអង្កេតពេញលេញ និងមានប្រសិទ្ធភាព ។ ការតម្រូវឱ្យមានសំអាងហេតុច្បាស់លាស់ គឺជាការចាំបាច់ដើម្បីផ្តល់យុត្តិធម៌ និងអនុញ្ញាតឱ្យភាគីយល់ដឹងពីមូលដ្ឋានសម្រេចសេចក្តី និងពិចារណាប្តឹងមកតុលាការជាន់ខ្ពស់ ឬក៏មិនប្តឹង ។ បើតាមតុលាការកំពូល ក្នុងសាលដីការបស់ខ្លួន បានអះអាងថា សំអាងហេតុមិនគ្រប់គ្រាន់មានន័យថាគ្មានសំអាងហេតុ (សាលដីកាតុលាការកំពូលលេខ ២៦៩ ចុះថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០១៣ ទំ.៥, សាលដីកាតុលាការកំពូលលេខ ១១៩ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៣ ទំ.៥ និងសាលដីកាតុលាការកំពូលលេខ ៣០៥ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ទំ.១១) ។ ហួសានី ទទួលស្គាល់ថាគាត់ប្រើប្រាស់សារធាតុញៀន គាត់ធ្លាប់ឱ្យលេខទូរស័ព្ទទៅឱ្យ យ៉ុន ដែលជាជនជាប់ចោទម្នាក់ក្នុងសំណុំរឿងនេះដែរ ។ ជនជាប់ចោទរូបនេះ (យ៉ុន) ត្រូវបានឃាត់ខ្លួនជាមួយសារធាតុញៀន ហើយនិយាយថាឱ្យហួសានី ២០០ ដុល្លារ ដែល ហួសានី ខ្លួនឯងថាមិនបានទទួលដូចនេះ ។ ការឃាត់ខ្លួនធ្វើឡើងដោយចៃដន្យក្នុងខណៈដែល ហួសានី បានទៅផ្ទះរបស់ យ៉ុន ដើម្បីខ្ចីម៉ូតូ ។ ព្រះរាជអាជ្ញាហាក់សង្កាត់ធ្ងន់ថា ហួសានី ផ្តល់លេខទូរស័ព្ទអ្នកលក់ថ្នាំនៅភ្នំពេញទៅ យ៉ុន នេះជាការជួយ ។ នេះនាំឱ្យមានការសម្រេចផ្តន្ទាទោស ហួសានី ហើយសាលាឧទ្ធរណ៍បានតម្កល់សាលក្រម ។ សាលដីកាលេខ ១៥៣ មិនមានសំអាងហេតុជាក់លាក់ ។ ដូចនេះបណ្តឹងសាទុក្ខនេះមានមូលហេតុក្នុងមាត្រា ៤១៩ ដែលតុលាការកំពូលអាចទទួលមកពិចារណាបាន ។ សាលដីកាដែលតម្កល់សាលក្រមលេខ ៤២៤ ដោយគាំទ្រនូវសំអាងហេតុក្នុងសាលក្រមនេះ តំណាងមហាអយ្យការសន្និដ្ឋានថា ៖ ...ហួសានី បានឆ្លើយសារភាពថា ពិតជាបានឱ្យលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនទៅឈ្មោះ យ៉ុន ហើយឈ្មោះនេះ ក្រោយពីបានលេខទូរស័ព្ទ ក៏បានទាក់ទងទៅទិញថ្នាំញៀនតាមលេខទូរស័ព្ទនោះ និងទិញថ្នាំបានមែន ។ ក្នុងផ្នែកការយល់ឃើញ សាលាឧទ្ធរណ៍អះអាងថា ៖...អំពីឱ្យលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនឱ្យទៅឈ្មោះ យ៉ុន ដើម្បីទិញគ្រឿងញៀនយកមកលក់បន្ត និងទទួលបានប្រាក់កម្រៃរបស់ឈ្មោះ ហួសានី គឺជាបទសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ក្រុមប្រឹក្សាជំនុំជម្រះជាទីគោរព ហួសានី បានសារភាពថាបានប្រើប្រាស់សារធាតុញៀន សារភាពថាឱ្យលេខទូរស័ព្ទ តែបដិសេធថាមិនបានទទួលលុយ ២០០ ដុល្លារ ដូចការអះអាងរបស់ចារីឈ្មោះ យ៉ុន ទេ ។ ហេតុនេះគាត់បានបដិសេធការសមគំនិតក្នុងការជួញដូរគ្រប់ដំណាក់កាលនៃនីតិវិធី ក៏ដូចមុខចៅក្រមសាលាឧទ្ធរណ៍ដែរ នេះហើយដែលនាំឱ្យគាត់ប្តឹងសាទុក្ខ ។ ហួសានី បានលេខទូរស័ព្ទពីអ្នកផ្សេង ។ មានភាពមិនច្បាស់លាស់ថា គាត់ឱ្យលេខទៅ យ៉ុន យូរ ឬឆាប់មុនឃាត់ខ្លួនក្នុងថ្ងៃទី១៦ តែបើតាមការបញ្ជាក់របស់ជនជាប់ចោទថាបានឱ្យលេខទូរស័ព្ទមុនពេលឃាត់ ៣ទៅ៤ខែមកហើយ ក្នុងន័យនេះចន្លោះពេលវេលានៃការផ្តល់លេខទូរស័ព្ទ (ជាហេតុ) និងនាំឱ្យមានការទាក់ទងទិញគ្រឿងញៀន (លទ្ធផល) អាចនៅឆ្ងាយ ។ ការជួយក្នុងទម្រង់សមគំនិត ទាមទារចេតនាជួយ ដែលក្នុងសំណុំ



Scanned with CamScanner

រឿងនេះគឺចេតនានៅពេលឱ្យលេខ ដើម្បីជួយដល់ការជួយដូរសារធាតុញៀន ។ ប្រសិនបើ ហ្វូសានី មិនឱ្យលេខទេ ក៏យ៉ុន អាចទទួលបានលេខពីអ្នកផ្សេងទៀតបានដែរ នេះមានន័យថា ការផ្តល់លេខដោយ ហ្វូសានី មិនមានឥទ្ធិពលអ្វីធំដុំលើទង្វើជួញដូរទេ ។ ឯកឧត្តមប្រធាន ប្រសិនបើការណ៍គ្រាន់តែឱ្យលេខទូរស័ព្ទគ្រប់គ្រាន់ជាបទសមគំនិត ដូចព្រះរាជអាជ្ញាអះអាង វាទំនងជាមនុស្សជាច្រើនក្នុងសង្គមអាចនឹងត្រូវបានចោទពីការជួយប្រព្រឹត្តបទល្មើសដែរហើយ ។ ដូចបានអះអាងខាងលើ ធាតុផ្សំសម្ភារៈ និងអត្តនោម័តនៃការជួញ ត្រូវមានភាពតឹងរ៉ឹងហួសពីនេះ ដោយសារថា ជនសមគំនិតមានទោសស្រដៀងនឹងចារី ឬអាចមានទោសខ្ពស់ជាង ។ សាលាឧទ្ធរណ៍អះអាងថា ហ្វូសានី បានទទួលលុយ ២០០ដុល្លារ តែ ហ្វូសានី ប្រកែក! យ៉ុន ជាចារីបាននិយាយដូចនេះ ។ ក្រុមប្រឹក្សាជាទីគោរព យ៉ុន ជាជនជាប់ចោទ ហើយច្បាប់មិនតម្រូវឱ្យធ្វើសម្បថមុននឹងនិយាយទេ ដូចនេះសេចក្តីថ្លែងរបស់គាត់តែឯងមិនគួរទុកចិត្តទេ បើគ្មានភស្តុតាងដទៃមកគាំទ្រ ។ ការដាក់ទោសមនុស្សម្នាក់ប៉ះសិទ្ធិសេរីភាព តម្រូវឱ្យមានភស្តុតាងច្រើន រឹងមាំ និងគាំទ្រគ្នា ។ តាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ចែងច្បាស់ណាស់ថា ដើម្បីដាក់ទោសជនសមគំនិតបានលុះត្រាបទល្មើសត្រូវបានប្រព្រឹត្ត ។ ក្នុងសំណុំរឿងនេះ វាទាមទារថាបទជួញដូរសារធាតុញៀន ត្រូវបានប្រព្រឹត្តដោយ យ៉ុន ។ ភស្តុតាងគ្រាន់តែបង្ហាញថា តាមរយៈជនជាប់ចោទ នគរបាលបានឃាត់ និងដកហូតសារធាតុញៀនពី យ៉ុន ហើយឃាត់ខ្លួន ហ្វូសានី នៅកន្លែងឃាត់ខ្លួន យ៉ុន ខណៈដែល ហ្វូសានី បានទៅខ្ចីម៉ូតូ (ឃាត់ដោយចៃដន្យគ្មានដីកា) ។ នេះមិនបង្ហាញថាបទ ជួញដូរ ត្រូវបានប្រព្រឹត្តទេ ។ វាអាចជាបទកាន់កាប់ ឬប្រើប្រាស់ដោយ យ៉ុន ក៏អាចថាបាន ។ ភស្តុតាងក្នុងសំណុំរឿងផ្តល់ដោយព្រះរាជអាជ្ញា មិនបានបង្ហាញអំពីធាតុផ្សំបទល្មើស និងទម្រង់ទទួលខុសត្រូវដែលតម្រូវហួសពីវិមតិសង្ស័យទេ ភស្តុតាងសរុបបង្ហាញអំពីមន្ទិលខ្លាំង ហើយបើតាមខ្លឹមសារមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ទិលជាប្រយោជន៍ដល់ជនជាប់ចោទ ។ បើតាមសាលដីកា មន្ទិលជាប្រយោជន៍ មានន័យថា ជនជាប់ចោទត្រូវបានដោះលែងឱ្យរួចខ្លួន ។ ជាសរុបសំអាងហេតុនាំឱ្យមានការសន្និដ្ឋានថា ហ្វូសានី សមគំនិតក្នុងទង្វើជួញដូរសារធាតុញៀន មានភាពមិនច្បាស់លាស់ ហើយដែលតាមមាត្រា ៤១៩ តុលាការកំពូលអាចទទួលយកបណ្តឹងសាទុក្ខនេះមកជម្រះបាន ។ ភស្តុតាង ហួសពីវិមតិសង្ស័យមិនបានបង្ហាញថា ហ្វូសានី បានសមគំនិតទេ ។ ហេតុដូច្នេះ ក្រុមប្រឹក្សាជំនុំជម្រះទទួលយកបណ្តឹងសាទុក្ខ បដិសេធសាលដីកាលេខ ១៥៣ និងតាមអនុលោមតាមមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌសុំសម្រេចឱ្យ ហ្វូសានី រួចផុតពីបទចោទប្រកាន់ ។

-លោកមេធាវី [redacted]ន្ទតារា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ហ្វូសានី បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានពិភាក្សាដេញដោលរួច ខ្លួនយល់ឃើញថាឈ្មោះ[redacted] ហ្វូសានី មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហេតុនេះបើយោងតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ស្តីពីចេតនាប្រព្រឹត្តបទល្មើសចែងថា "ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត" ។ ក្នុងរឿងនេះខ្លួនពិនិត្យឃើញថា កូនក្តីខ្លួនពុំបាន



Scanned with CamScanner

ចេតនាក្នុងការប្រព្រឹត្តបទល្មើស ឬក៏សមគំនិតជាមួយឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន នោះទេ គឺគាត់គ្រាន់តែបានឱ្យលេខទូរស័ព្ទទៅឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន ហើយការឱ្យលេខទូរស័ព្ទនោះគឺបានឱ្យតាំងពី ៤ខែមុនពេលចាប់ខ្លួនមកម្លេះ ។ មួយវិញទៀតបើផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ក្នុងចំណុចនេះគឺគ្មានភស្តុតាងណាមួយ ដែលបញ្ជាក់ថា កូនក្តីខ្លួនមានចេតនា ក្នុងការប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះទេ ។ ចំណុចមួយទៀត ទាក់ទងនឹងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌស្តីពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ចែងថា "បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។ នៅក្នុងអង្គហេតុរឿងក្តីនេះដែរ គឺថាឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន និងកូនក្តីខ្លួន គ្រាន់តែជាអ្នកស្គាល់គ្នាហើយឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន បានសុំលេខទូរស័ព្ទពីកូនក្តីខ្លួនដើម្បីទំនាក់ទំនងទៅអ្នកលក់គ្រឿងញៀនដោយផ្ទាល់ល ហើយកូនក្តីរបស់ខ្លួន មិនបានទទួលផលប្រយោជន៍អ្វីពីឈ្មោះ [redacted] ច័ន្ទវ៉ាយ៉ុន នោះទេ ។ មួយវិញទៀតទាក់ទងនឹងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាការប្រកាសពីពិរុទ្ធភាព "ប្រសិនបើតុលាការយល់ឃើញថា អំពើនេះពុំមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ" ។ ដោយយោងតាមចំណុចមាត្រាទាំងអស់នេះហើយជាចុងក្រោយខ្លួនសំណូមពរដល់ឯកឧត្តមប្រធានក្រុមប្រឹក្សាមេត្តាសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ហ្សាទីបានរួចផុតពីបទចោទប្រកាន់ និងសុំដោះលែងកូនក្តីរបស់ខ្លួនឱ្យមានសេរីភាពឡើងវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០០១ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០២២ របស់ជនជាប់ចោទ [redacted] ហ្សាទី ហៅ លីប ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នាពេលពិភាក្សាដេញដោលនេះ ក៏ដូចជានៅក្នុងសារណាការពារ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២២ និងនៅក្នុងសេចក្តីសន្និដ្ឋានការពារចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០២៣ ដែរ ជនជាប់ចោទ [redacted] ហ្សាទី និងមេធាវីការពារសិទ្ធិជនជាប់ចោទ បានសុំឱ្យតុលាការកំពូលសម្រេច បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១៥៣/១៩ ព្រទ.ក្រVI ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សាលាឧទ្ធរណ៍ព្រះសីហនុ និងសម្រេចឱ្យ



Scanned with CamScanner

ជនជាប់ចោទ [redacted] ហួសានី រួចខ្លួនពីបទចោទ និងដោះលែងជនជាប់ចោទឱ្យមានសេរីភាព នោះ តុលាការកំពូលពិនិត្យឃើញថា ជនជាប់ចោទ [redacted] ហួសានី និងមេធាវីការពារសិទ្ធិជនជាប់ចោទ មិនបានលើកការតវ៉ាទៅនឹងការកំណត់ពិរុទ្ធ ភាពលើជនជាប់ចោទ [redacted] ហួសានី ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះទេ នោះ តុលាការកំពូលមិនចាំបាច់ពិចារណាចំពោះការអនុវត្តច្បាប់ របស់តុលាការអង្គហេតុទាក់ទងនឹងបទល្មើសនេះទេ ។

៣-យល់ឃើញថា មេធាវីការពារសិទ្ធិជនជាប់ចោទ បានលើកឡើងអំពីកំហុសក្នុងការអនុវត្តច្បាប់របស់សាលាឧទ្ធរណ៍ព្រះសីហនុ ចំពោះការសម្រេចសេចក្តី ដោយសារអំពើប្រព្រឹត្តរបស់ជនជាប់ចោទ [redacted] ហួសានី មិនបានបំពេញនូវធាតុ *ចេតនាទុច្ចរិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមនិយមន័យនៃអ្នកសមគំនិត តាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងចំណុចទី ៦ នៃកថាខណ្ឌទី ៥ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនទេ ហើយវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ដោយលើកហេតុផលថា ជនជាប់ចោទបានឱ្យលេខទូរស័ព្ទទៅចារ [redacted] ត័ន្តវ៉ាយ៉ុន ហៅ កូម៉ា មែន ប៉ុន្តែការឱ្យនេះតាំងពីបួនទៅប្រាំខែមុនថ្ងៃប្រព្រឹត្តអំពើល្មើសរបស់ចារី [redacted] ត័ន្តវ៉ាយ៉ុន ដែលចន្លោះពេលវេលានៃការផ្តល់លេខទូរស័ព្ទ និងការប្រព្រឹត្តបទល្មើសនៅឆ្ងាយពីគ្នាពេក ហើយចារី [redacted] ត័ន្តវ៉ាយ៉ុន ក៏អាចទទួលលេខពីអ្នកផ្សេងបានដែរ ក្នុងន័យនេះ ការផ្តល់លេខទូរស័ព្ទដោយជនជាប់ចោទ [redacted] ហួសានី មិនមានឥទ្ធិពលអ្វីធំដុំលើទង្វើជួញដូរទេ* នោះ តុលាការកំពូលពិនិត្យលើបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ បានកំណត់អំពីនិយមន័យនៃអ្នកសមគំនិតដែលទាក់ទងនឹងរឿងក្តីនេះថា ជាអ្នកជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន ដែលក្នុងន័យនៃមាត្រានេះ តុលាការកំពូលពិចារណាឃើញថា មាត្រានេះមិនបានកំណត់អំពីរយៈពេលនៃការជួយសំរួលជាការផ្តល់ជំនួយ ឬ គម្លាតពីគ្នារវាងការផ្តល់ជំនួយ និងការប្រព្រឹត្តបទល្មើសរបស់ចារី ធ្វើជាមូលដ្ឋាននៃការកំណត់អំពីចេតនាទុច្ចរិតរបស់អ្នកសមគំនិត ឬ ថាជាអ្នកសមគំនិតទេ ប៉ុន្តែបញ្ហាសំខាន់ និងជាមូលដ្ឋាននៃការកំណត់ពីចេតនាទុច្ចរិតរបស់អ្នកសមគំនិតនេះត្រង់ថា អ្នកផ្តល់ជំនួយដល់បុគ្គលណាម្នាក់ ដែលអ្នកផ្តល់មិនបានដឹងជាក់ច្បាស់ក្នុងស្ថានភាពទូទៅថាយកទៅដើម្បីប្រព្រឹត្តបទល្មើស អ្នកផ្តល់នោះមិនត្រូវបានចាត់ទុកថា ជាអ្នកសមគំនិតចំពោះអំពើប្រព្រឹត្តរបស់ចារីដែលបានប្រព្រឹត្តបទល្មើសដោយសារការផ្តល់ជំនួយនោះទេ ។ ផ្ទុយទៅវិញត្រូវបានចាត់ទុកថា ជាអ្នកជួយសម្រួលដោយចេតនាក្នុងឋានៈជាអ្នកសមគំនិតក្នុងបទល្មើសរបស់ចារី ចំពោះអ្នកផ្តល់ជំនួយដែលបានដឹងច្បាស់ និងមានចេតនាជាក់លាក់ឱ្យការប្រព្រឹត្តបទល្មើលរបស់ចារីកើតឡើង តាមរយៈការផ្តល់ជំនួយរបស់ខ្លួន និងបានដឹងច្បាស់ថា អ្នកដែលខ្លួនផ្តល់ជំនួយនោះ ជាចារីនៃបទល្មើស ឬ ទោះបីមិនបានដឹងថាជាចារី ឬ មិនស្គាល់ក៏ដោយ តែអ្នកផ្តល់ជំនួយនៅតែផ្តល់ជំនួយដល់ជននោះ ដែលក្នុងស្ថានភាពទូទៅមិនគប្បីផ្តល់ឱ្យ នោះអ្នកផ្តល់ជំនួយនឹងត្រូវទទួលយកនូវលទ្ធផលនៃបទល្មើសរបស់ចារីនោះ ក្នុងឋានៈជាអ្នកសម



Scanned with CamScanner

គំនិតដែរ ។ ក្នុងរឿងក្ដីនេះ ជនជាប់ចោទ [redacted] ហួសានី ស្គាល់គ្នា មានទំនាក់ទំនងគ្នា ព្រមទាំងដឹងច្បាស់ថា ចារី [redacted] ទ្ធវ៉ាយ៉ុន ជាចារីនៃបទល្មើសជួញដូរគ្រឿងញៀន ទើបបានផ្ដល់ជំនួយជាលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនឈ្មោះ ង៉ុក ទៅឱ្យចារី [redacted] ច័ន្ទវ៉ាយ៉ុន ដើម្បីរកស៊ីជួញដូរគ្រឿងញៀនបន្តទៀត ហើយត្រូវបានចារី [redacted] ច័ន្ទវ៉ាយ៉ុន ធ្វើទំនាក់ទំនងទិញគ្រឿងញៀនពីឈ្មោះ ង៉ុក តាមមធ្យោបាយលេខទូរស័ព្ទដែលជនជាប់ចោទ [redacted] ហួសានី ផ្ដល់ឱ្យ រហូតសមត្ថកិច្ចដឹង និងចាប់បានថ្នាំញៀនពីរថយន្តដឹកជញ្ជូន វីរៈ ប៊ុនថាំ ដូចមានចម្លើយបញ្ជាក់ និងមានភាពស៊ីសង្វាក់គ្នារបស់ជនជាប់ចោទ [redacted] ហួសានី និងចារី [redacted] ច័ន្ទវ៉ាយ៉ុន ដែលឆ្លើយបញ្ជាក់ថា ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ ង៉ុក កាលពីថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២០ ដោយប្រើទូរស័ព្ទដែលលេខ [redacted] តាមរយៈការផ្ដល់ឱ្យដោយជនជាប់ចោទ [redacted] ហួសានី ឃើញថា ជនជាប់ចោទ [redacted] ហួសានី មានចេតនាទុច្ចរិតតាមរយៈការផ្ដល់លេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនឈ្មោះ ង៉ុក ដល់ការប្រព្រឹត្តអំពើជួញដូររបស់ចារី [redacted] ច័ន្ទវ៉ាយ៉ុន ។ ដូច្នេះ ការកំណត់របស់តុលាការអង្គហេតុលើជនជាប់ចោទ [redacted] ហួសានី ក្នុងឋានៈជាអ្នកសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនរបស់ចារី [redacted] ច័ន្ទវ៉ាយ៉ុន តាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងការប្រកាសផ្ដន្ទាទោសជនជាប់ចោទ [redacted] ហួសានី តាមបញ្ញត្តិចំណុចទី ៦ កថាខណ្ឌទី ៥ នៃមាត្រា ៤០ ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន មិនមានកំហុសក្នុងការអនុវត្តច្បាប់ទេ ហើយសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ដែលបញ្ជាក់អំពីភស្តុតាងកំណត់ពិរុទ្ធភាពលើជនជាប់ចោទ [redacted] ហួសានី និងសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ព្រះសីហនុ មានភាពត្រឹមត្រូវតាមច្បាប់ ឃើញថា បណ្ដឹងសាទុក្ខត្រង់ផ្នែកនេះ របស់ជនជាប់ចោទ [redacted] ហួសានី មិនមានមូលហេតុដូចមានកំណត់តាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៤-យល់ឃើញថា ការលើកមូលហេតុរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ [redacted] ហួសានី ដែលថា ការវិនិច្ឆ័យសេចក្ដីរបស់សាលាឧទ្ធរណ៍ព្រះសីហនុ មិនមានសំអាងហេតុ ឬ កង្វះសំអាងហេតុ នោះ តុលាការកំពូលពិនិត្យឃើញថា នៅក្នុងនីតិវិធីបណ្ដឹងចាប់ពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលជំនុំជម្រះនៅសាលាឧទ្ធរណ៍ព្រះសីហនុ ជនជាប់ចោទ [redacted] ហួសានី ក្ដី និងមេធាវីការពារសិទ្ធិជនជាប់ចោទក្ដី មិនដែលបានលើកឡើងអំពីរយៈពេលបួន ឬ ប្រាំខែ ឬ គម្លាតគ្នារវាងការផ្ដល់លេខទូរស័ព្ទ និងការប្រព្រឹត្តបទល្មើស ធ្វើជាមូលដ្ឋាននៃការតវ៉ាទៅនឹងការចោទប្រកាន់ ឬ *ដែលមិនអាចកំណត់អំពីចេតនាទុច្ចរិតរបស់ជនជាប់ចោទ* [redacted] *ហួសានី ក្នុងឋានៈជាអ្នកសមគំនិត* នោះឡើយ ផ្ទុយទៅវិញសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីបានទទួលស្គាល់ថា ជនជាប់ចោទ [redacted] ហួសានី បានទទួលស្គាល់កំហុសរបស់ខ្លួនហើយ ហើយទោះបីមានចម្លើយបដិសេធនៅសាលាឧទ្ធរណ៍ព្រះសីហនុក៏ដោយ ក៏មិនបានលើកពាក្យពេចន៍នេះដែរ នោះ តុលាការកំពូលពិចារណាឃើញថា ការមិនលើកជាសំអាងហេតុរបស់តុលាការអង្គហេតុដោយសារមិនមានការលើកឡើងពីជនជាប់ចោទ និងមេធាវីការពារសិទ្ធិនោះ មិនមានកំហុសក្នុងការអនុវត្តច្បាប់ទេ ។ ម្យ៉ាងទៀត ការលើកឡើង



Scanned with CamScanner

របស់មេធាវីការពារសិទ្ធិជនជាប់ចោទ [redacted] ហួសានី អំពីការបដិសេធថា មិនបានទទួលប្រាក់ ២០០ (ពីររយ) ដុល្លារអាមេរិក ពីចារី [redacted] ច័ន្ទរ៉ាយ៉ុន ធ្វើជាមូលដ្ឋានដោះបន្ទុកថា មិនមានធាតុផ្សំគ្រប់គ្រាន់ជាអ្នកសមគំនិត និងតវ៉ាលើសំអាងហេតុដែលថា ជនជាប់ចោទ [redacted] ហួសានី ទទួលប្រាក់ ២០០ ដុល្លារ នោះ តុលាការកំពូលពិនិត្យឃើញថា ចំពោះប្រាក់ដែលចារីនៃបទល្មើសផ្តល់ជូនដល់អ្នកជួយសម្រួល(អ្នកសមគំនិត) ឬ មិនផ្តល់នោះ បញ្ញត្តិនៃមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មិនបានកំណត់ថាជាធាតុផ្សំនៃចេតនារបស់អ្នកសមគំនិត ឬថាមិនមែនជាធាតុផ្សំសំខាន់នៃចេតនាទុច្ចរិតរបស់អ្នកសមគំនិតនោះទេ ហើយទោះជាយ៉ាងនេះក្តី ក៏ការលើកការជំទាស់របស់មេធាវីការពារសិទ្ធិជនជាប់ចោទ ជាការភាន់ច្រឡំលើខ្លឹមសារនៃសំអាងហេតុ ផ្ទុយទៅវិញតាមសំអាងហេតុពិតនៃសាលក្រមរបស់សាលាដំបូងខេត្តព្រះសីហនុ ការប្រើពាក្យ *សន្យានឹងឱ្យប្រាក់ ២០០ ដុល្លារ* និងសាលដីការបស់សាលាឧទ្ធរណ៍ព្រះសីហនុ ការប្រើពាក្យ *នឹងឱ្យប្រាក់ ២០០ ដុល្លារទៅជនជាប់ចោទ ម៉ើល ហួសានី* ជាពាក្យពេចន៍ដែលមានខ្លឹមសារបញ្ជាក់ថា ជនជាប់ចោទ [redacted] ហួសានី មិនទាន់ទទួលបានប្រាក់ ២០០ ដុល្លារ ដូចការឆ្លើយបដិសេធរបស់ជនជាប់ចោទ [redacted] ហួសានី ដែលថាមិនបានទទួលប្រាក់ ២០០ ដុល្លារ មែន និងជាពាក្យពេចន៍ដែលតុលាការអង្គហេតុលើកឡើងតាមការឆ្លើយបញ្ជាក់របស់ចារី [redacted] ច័ន្ទរ៉ាយ៉ុន ដែលបង្ហាញពីឆន្ទៈ និងការទំនាក់ទំនងគ្នារវាងជនជាប់ចោទ [redacted] ហួសានី និងចារី [redacted] ច័ន្ទរ៉ាយ៉ុន ក្នុងឋានៈជាអ្នកសមគំនិត និងចារីនៃបទល្មើសប៉ុណ្ណោះ ឃើញថា បណ្តឹងសាទុក្ខត្រង់ផ្នែកនេះរបស់ជនជាប់ចោទ [redacted] ហួសានី មិនមានមូលហេតុដូចមានកំណត់តាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៥-យល់ឃើញថា ការដែលតុលាការអង្គហេតុសម្រេចប្រកាសពិរុទ្ធភាព និងផ្តន្ទាទោសលើជនជាប់ចោទ [redacted] ហួសានី ពីបទ សមគំនិត តាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ជាការមិនត្រឹមត្រូវតាមបញ្ញត្តិនៃមាត្រានេះទេ តុលាការកំពូលពិនិត្យឃើញថា មាត្រា ២៩ នេះ បានកំណត់ជាក់លាក់អំពី *និយមន័យនៃអ្នកសមគំនិត* ដែលជា បញ្ញត្តិកំណត់អំពី *ឋានៈនៃការទទួលខុសត្រូវព្រហ្មទណ្ឌ* របស់ជនប្រព្រឹត្តបទល្មើសច្រើននាក់ ដែលទាក់ទងនឹងរឿងក្តីនេះ ការប្រព្រឹត្តបទល្មើសដោយមានពិរុទ្ធជន [redacted] ច័ន្ទរ៉ាយ៉ុន ក្នុងឋានៈជាចារី(ជនដែដល់) នៃបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ចំណែកជនជាប់ចោទ [redacted] ហួសានី ក្នុងឋានៈជា*អ្នកសមគំនិត* ក្នុងបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយក្រមព្រហ្មទណ្ឌ មិនមានចែងកំណត់ពីបទសមគំនិត ក្នុងមាត្រាណាផ្សេងទេ ឃើញថា តុលាការកំពូល គប្បីកែប្រែការសម្រេចសេចក្តីដែលភាន់ច្រឡំរបស់តុលាការអង្គហេតុ ឱ្យបានត្រឹមត្រូវ ទុកជាប្រយោជន៍ច្បាប់ ដោយមិនចាំបាច់បង្វិលរឿងក្តី តាមបញ្ញត្តិមាត្រា ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៥៣/១៩ ព្រទ.ក្រVI ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ព្រះសីហនុ ដែលសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ខ្លះ ខុសខ្លះ ។



Scanned with CamScanner

ហេតុដូច្នេះ

សម្រេច

១.បដិសេធ បណ្តឹងសាទុក្ខលេខ ០០១ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០២២ របស់ជនជាប់ចោទ [redacted] ហួសាធី ហៅ លីប ។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ១៥៣/១៩ ព្រទ.ក្រVI ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២១ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ព្រះសីហនុ លើកលែងតែសាលក្រមព្រហ្មទណ្ឌលេខ ៤២៤/៤៥ (ជ) ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់សេចក្តីសម្រេចចំណុចទី ៣ ដែលសរសេរថា "ពីបទ សមគំនិតក្នុងអំពើជួញដូរ" ត្រូវកែប្រែទៅជា "ពីបទ ជួញដូរ" វិញ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២៣ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣ ។

សមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| លោក | [redacted] | ជាក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើមឲ្យ

ថ្ងៃចន្ទ ៦ កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ថ្ងៃចន្ទ ៦ កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner

"យើង [redacted]ថាចរិត់ ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះ បានចូលជាស្ថាពរ នៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣ និងមានអានុភាពអនុវត្តតាមច្បាប់។"

"សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ថ្នាក់ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ៗ"

ថ្ងៃចន្ទ ៦ កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២៣

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner